ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០១ សរ

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

# សារាចរ

## ស្តីពី

## គោលការណ៍ជ្រើសរើសអោយចូលក្នុងក្របខណ្ឌរដ្ឋ និងគោលការណ៍ជ្រើសរើសបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងស្ថាប័ននានា

រាជរដ្ឋាភិបាលជម្រាបជូន ឯកឧត្តមគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋានដើម្បីជ្រាបថា ដោយអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីល ជាទូទៅការជ្រើសរើសអោយចូលក្នុងក្របខណ្ឌរដ្ឋត្រូវធ្វើឡើងដោយការប្រឡងប្រជែង។ ដូច្នេះគ្រប់ក្រសួងស្ថាប័ន ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម ៖

– ក្រសួង ស្ថាប័ននីមួយៗ ដែលត្រូវការជ្រើសរើសមន្ត្រីរាជការ ត្រូវធ្វើសំណើមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់សំណើនេះទៅក្នុងថវិកានៃឆ្នាំនីមួយៗ ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច មុននឹងដាក់ជូនរដ្ឋសភាអនុម័ត។ ក្រោយពីរដ្ឋសភាអនុម័តលើគម្រោងក្របខណ្ឌតាមស្ថាប័ននីមួយៗរួច ទើបសាមីស្ថាប័នដំណើរការជ្រើសរើសអោយចូលក្នុងក្របខណ្ឌដោយមានការប្រឡងប្រជែងទៅតាមល័ក្ខខ័ណ្ឌនៃច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន។

– ក្នុងករណីពិសេស បើមានសេចក្តីត្រូវការបុគ្គលិក ក្រៅពីគម្រោងប្រចាំឆ្នាំដូចខាងលើ ក្រសួងស្ថាប័នត្រូវធ្វើសំណើមករដ្ឋលេខាធិការមុខងារសាធារណៈ ដែលនឹងពិចារណា និងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរាយការណ៍ និងសុំយោបល់ពីគណៈរដ្ឋមន្ត្រី។ ក្នុងករណីដែលមានចម្លើយជាវិជ្ជមាន ស្ថាប័នសាមីអាចចាត់ការជ្រើសរើសដោយប្រឡងប្រជែងអោយចូលក្នុងក្របខណ្ឌបន្ថែមបាន ប៉ុន្តែករណីនេះត្រូវតែបញ្ចូលទៅក្នុងថវិកាកែប្រែនៃឆ្នាំ។

ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានសង្កេតឃើញថា កន្លងមកស្ថាប័នមួយចំនួន ដែលមានសាលាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ បានធ្វើការប្រឡងជ្រើសរើសនិស្សិតអោយចូលរៀនជារៀងរាល់ឆ្នាំទៅតាមមុខជំនាញបច្ចេក-ទេសរបស់ក្រសួងសាមី លុះដល់ពេលចប់វគ្គសិក្សាក្រសួងទាំងនោះមានបញ្ហាចោទឡើងអំពីការដោះស្រាយការងារជូននិស្សិតបណ្តុះបណ្តាលបច្ចេកទេសទាំងនោះ ។

ចំពោះមុខ ដើម្បីដំណើរការការងារអភិវឌ្ឍន៍ធនធានមនុស្សរបស់រដ្ឋមន្ត្រីរបស់រដ្ឋអោយមានប្រសិទ្ធភាពខ្ពស់ឆ្លើយតបបានទិសដៅនៃការកែទម្រង់រដ្ឋបាល ដែលតម្រូវអោយមានការផ្លាស់ប្តូរនូវបែបបទជ្រើសរើសបណ្តុះបណ្តាល រាជរដ្ឋាភិបាលមានវិធានការដូចតទៅនេះ ៖

ការកសាងផែនការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ត្រូវមានតុល្យភាព និងស៊ីសង្វាក់ជាមួយនឹងតម្រូវ-ការប្រើប្រាស់នៃក្របខណ្ឌរដ្ឋ ដូច្នេះគ្រប់ក្រសួងស្ថាប័ន ដែលមានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈត្រូវធ្វើការពិភាក្សាជាមុនអំពីចំនួន និងទិសដៅនៃការបណ្តុះបណ្តាលនោះ ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យវាយតម្លៃ រាយការណ៍ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុត្តតាមខ្លឹមសារខាងលើនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រី ទី ១** **នាយករដ្ឋមន្ត្រី ទី ២**

**ហត្ថលេខា និងត្រា** **ហត្ថលេខា និងត្រា**

**នរោត្តម រណឫទ្ធិ** **ហ៊ុនសែន**